# អង្គជំនុំជម្រះសាលាដំបូងសម្រេចលើគម្រោងស្នើសុំសំណងជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីសំណុំរឿង០០២

**អាន ហាញខុល**

**ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣**

*ប្រែសម្រួលដោយ នង ច័ន្ទមល្លិកា*

អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា សហមេធាវីនាំមុខ ដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកគម្រោងស្នើសុំសំណងជួសជុលការខូចខាតក្នុងករណីសំណុំរឿង០០២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថា មានលក្ខណៈសមរម្យសម្រាប់ការតាមដានពីផលប៉ះពាល់របស់ជនរងគ្រោះ នឹងត្រូវបានតុលាការសម្រេចអនុម័ត“ជាគោលការណ៍” ។ ទោះបីជាយ៉ាងនេះក្តី មិនទាន់មានការអះអាងឲ្យច្បាស់លាស់ណាមួយ ទៅលើដំណើរតាមដានដោយការអនុម័តរបស់ខាងតុលាការ អាស្រ័យលើភាពស្រពេចស្រពិលចំពោះលទ្ធភាពរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះ ដើម្បីទទួលបាននូវការជ្រោមជ្រែងពីខាងរាជរដ្ឋាភិបាល សម្រាប់គម្រោងមួយចំនួនដើម្បីបញ្ជាក់នូវរាល់ព័ត៌មានលម្អិតបន្ថែមតំណាងឲ្យជនរងគ្រោះដទៃទៀត និងសំខាន់ជាងនេះទៀត នោះគឺភាពគ្រប់គ្រាន់ក្នុងការបែងចែកមូលនិធិសម្រាប់អនុវត្តរាល់គម្រោងទាំងអស់ ដែលនឹងត្រូវបញ្ចប់នាបំណាច់ខែកញ្ញា ខាងមុខនេះ ។

ខណៈពេលសាលក្រមករណីសំណុំរឿង០០១ត្រូវបាន ប្រកាសវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ធានាលើសំណងជួសជុលការខូចខាត ដូចមានចែង “ការប្រឆាំងលើការសម្រេចឲ្យសំណង ហើយ...ទទួលយកដោយទណ្ឌិត” ។ អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ពុំមានយុត្តាធិការណាមួយ ធានាឲ្យអាជ្ញាធរមានសមត្ថកិច្ច ផ្តល់នូវសំណងជួសជុលការខូចខាត ទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ដោយឡែកមានតែជំរុញឲ្យខាងអាជ្ញាធរមានសមត្ថកិច្ចនិងភាគីដទៃទៀតជួយជ្រោមជ្រែងខាងហិរញ្ញវត្ថុនិងតាមទម្រង់ផ្សេងៗទៀត ។ អង្គជំនុំជម្រះសាលាដំបូងក៏បានលើកឡើងថា ពុំមានយន្តការច្បាប់ណាមួយ “តម្រូវឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើការសងប្តូបំពេញសំណងប្រឆាំងនឹងជនជាប់ចោទជាមួយនឹងមូលនិធិដែលបានមកពីអាជ្ញាធរជាតិ និងភាគីជាដៃគូនោះទេ” ។ ជនជាប់ចោទត្រូវបានតុលាការមើលឃើញថាពិតជាលំបាក និងគ្មានលទ្ធភាព ហើយអង្គជំនុំជម្រះសាលាដំបូងសម្រេចឲ្យសំណងដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រឹមតែបញ្ចូលឈ្មោះរបស់គាត់ និងជនរងគ្រោះដែលរងគ្រោះផ្ទាល់មួយចំនួនទៀតក្នុងការចូលរួមសម្រេចសាលក្រម ចុងក្រោយការចង


66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ក្រុង និងការបោះពុម្ពផ្សាយលិខិតសុំអភ័យទោសរបស់ជនជាប់ចោទនៅក្នុងការជំនុំជម្រះ ។ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលនូវសំណើសុំសំណងជួសជុលការខូចខាតទាំងអស់ ទាំងការកសាងវត្តអារាម និងកន្លែងសម្រាប់រំឭកពិធី ការព្យាបាលដោយមិនគិតថ្លៃមូលនិធិសម្រាប់កម្មវិធីអប់រំលើប្រវត្តិសាស្ត្រខ្មែរក្រហមនិងការសិក្សាផ្សេងៗទៀត ទាមទារឲ្យមានការជ្រោមជ្រែងពីសំណាក់រាជរដ្ឋាភិបាល ដូចជា ថ្ងៃរំឭកបុណ្យជាតិ ។

ការរំពឹងទុកចំពោះអង្គជំនុំជម្រះលើកទីពីរក្នុងតុលាការ ចៅក្រមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានធ្វើវិសោធនកម្មវិធានច្បាប់តុលាការក្នុងការពង្រីកវិសាលភាពដែនសមត្ថកិច្ចរបស់ខ្លួនក្នុងការសម្រេចផ្តល់សំណងជួសជុលការខូចខាត ។ វិធានផ្ទៃក្នុងថ្មីទី២៣ស្ទួនចែងថា ផ្តល់សិទ្ធអំណាចដល់ចៅក្រមក្នុង ការ «វិនិច្ឆ័យលើគម្រោងជាក់លាក់មួយដែលមានឥទ្ធិពលសមរម្យ ដល់ការសម្រេចផ្តល់សំណងទាមទារដោយសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ហើយមានលទ្ធភាពក្នុងការអនុវត្ត ។ គម្រោងបែបនោះគួរតែមានការរៀបចំ និងទទួលស្គាល់ ដោយសហការជាមួយនឹងផ្នែកទ្រទ្រង់ជនរងគ្រោះ និងសុវត្ថិភាពគ្រប់គ្រាប់ក្នុងការទទួលយកមូលនិធិខាងក្រៅ» ។

ដោយតំណាងឲ្យអង្គជំនុំជម្រះសាលាដំបូង សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីនៅចុងឆ្នាំមុន បានធ្វើការកំណត់នូវអាទិភាពគម្រោងសំណងជួសជុលការខូចខាត និងមូលនីធិហិរញ្ញ វត្ថុខាងក្រៅថ្មីៗនេះ បានលើកឡើងពីអាទិភាពនូវគម្រោងសំណងទាំងប្រាំពីររួមមានដូចតទៅ ៖ ទី១) ការទទួលស្គាល់របស់រាជរដ្ឋាភិបាលចំពោះថ្ងៃចងចាំថ្មីសម្រាប់រំឭកដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ទី២) ការបង្កើតនូវទីតាំងសម្រាប់រំឭកពិធីជាសាធារណៈ ចំនួនពីបីទៅប្រាំមួយកន្លែង ដើម្បីជាការទទួលស្គាល់នូវផលប៉ះពាល់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងករណីសំណុំរឿង០០២ ដូចជា មូលនីធិសេវាកម្មសម្រាប់ព្យាបាល សុខភាពផ្លូវចិត្តចំពោះដើមបណ្តឹងរដ្ឋប្បវេណីក្នុងករណីសំណុំរឿង០០២ ទី៣) វិធីព្យាបាលដល់សាក្សី ទី៤) ក្រុមស៊ុយជំនួយទី៥ ពិព័រណ៍ចល័តដោយការបញ្ចាំងនូវកុនឯកសារខ្លី និងការផ្តល់សក្ខីកម្មផ្ទាល់ដោយដើមបណ្តឹងរដ្ឋប្បវេណី ទី៦) ទីតាំងពិព័រណ៍អចិន្ត្រៃយ៍ រួមមាន ឯកសារផ្សេងៗ ការផ្តល់សក្ខីកម្មតាមប្រព័ន្ធពហុព័ត៌មាន និងការដាក់តាំងជារូបភាពច្នៃប្រឌិតទាក់ទងនឹងការឈឺចាប់ និងផលប៉ះពាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ទី៧) កូនសៀវភៅព័ត៌មានដែលបកស្រាយ និងពន្យល់អំពីដំណើរការកាត់ក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងឧក្រិដ្ឋកម្មជុំវិញករណីសំណុំរឿង០០២ ។

អង្គជំនុំជម្រះសាលាដំបូង បានរៀបរាប់ខាងដើមរួចហើយ ក្នុងវិធានផ្ទៃក្នុងទី២៣ស្ទួនថាការផ្តួចផ្តើមទាំងនេះ ទាមទារឲ្យខាងរាជរដ្ឋាភិបាលកម្ពុជាមានសកម្មភាព «ដែលមានការអនុម័តដោយអង្គជំនុំ

ជម្រះសាលាដំបូង ជាសំណងជួសជុលដល់ការខូចខាត ហើយនេះជាការវាស់ស្ទង់សបញ្ជាក់ច្បាស់ពីការអនុម័ត និងអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា» ។ នៅដើមឆ្នាំនេះ មេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំដល់នាយករដ្ឋមន្ត្រី «ផ្ដល់ជាទិសដៅ ឬសេចក្ដីសម្រេចពាក់ព័ន្ធនឹងដែនសមត្ថកិច្ចរបស់រដ្ឋាភិបាល» សម្រាប់ការអនុវត្តនូវថ្ងៃចងចាំថ្មី ការរក្សានូវទីតាំងឧក្រិដ្ឋកម្មមួយចំនួនដែលមានចុះនូវដីការបញ្ជូនសំណុំរឿងទៅជំនុំជម្រះក្នុងករណី០០២ ការកសាងនូវទីសក្ការៈ និងទីតាំងរំឭកពិធី ការបង្កើតជាបណ្ណសារ និងទីតាំងពិព័រណ៍ ការសហការដាក់បញ្ចូលនូវប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សាកម្រិតជាតិពីថ្នាក់ទី៧ដល់ថ្នាក់ទី១២ ។ ជាកិច្ចឆ្លើយតប ទីស្ដីការគណៈរដ្ឋមន្ត្រីបានយល់ស្របថា «ស្ថិតក្នុងគោលការណ៍» ត្រូវតែចាត់ចែងសារជាថ្មីនៅថ្ងៃទី២០ ខែឧសភា ថៃដែលបានបង្កើតតាំងពីឆ្នាំ១៩៨៤ «ជាថ្ងៃចងកំហឹង» និង «ជាថ្ងៃចងចាំ» និងដើម្បីពង្រីកវិសាលភាពនៃការអប់រំពីរបបខ្មែរក្រហមដែលថ្មីៗនេះមានត្រឹមពីថ្នាក់ទី៩ដល់ទី១២ ឲ្យដល់ថ្នាក់ទី៧និងថ្នាក់ទី៨បន្ថែមទៀត ។ មិនមានគម្រោងណាផ្សេងទៀតនៅឡើយទេ ត្រូវបានគេរៀបរាប់ឲ្យបានលម្អិត គាំទ្រដល់ការស្នើសុំដោយមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ។ ខាងទីស្ដីការគណៈរដ្ឋមន្ត្រីសង្កត់ធ្ងន់ថា ជាការពិតណាស់ រាល់បញ្ហា ពាក់ព័ន្ធទាំងអស់គួរតែតម្រង់ទិសទៅរកក្រសួងដែលពាក់ព័ន្ធ និងអាជ្ញាធរក្នុងតំបន់លើប្រធានបទទាំងនេះ តែត្រូវចងចាំថា ភ្នាក់ងាររកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានកាតព្វកិច្ចស្វះស្វែងរក«ការជ្រោមជ្រែងខាងផ្នែកបច្ចេកទេស ក៏ដូចជាខាងហិរញ្ញវត្ថុ» សម្រាប់ការអនុវត្តនៅរាល់គម្រោងទាំងអស់ដែលបានស្នើសុំ ។

ជាកំណត់ហេតុចំណាំថ្មីរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណងជួសជុលការខូចខាត ចង្អុលបង្ហាញថា ពុំមានបន្តនូវការប្រឹក្សារវាងមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី និងរាជរដ្ឋាភិបាលលើគម្រោងចំពោះការបង្កើតនូវថ្ងៃចងចាំទៀតទេ ។ ម្យ៉ាងវិញទៀត «កាលបរិច្ឆេទលើការផ្ដួចផ្ដើមនូវទីតាំងរំឭកពិធីជាសាធារណៈ ដែលសហការដោយរាជរដ្ឋាភិបាលមិនទាន់ច្បាស់លាស់នៅឡើយទេ» ។ អាស្រ័យហេតុដូច្នេះហើយ ទើបអង្គជំនុំជម្រះសាលាដំបូង ទាមទារឆន្ទះរបស់រាជរដ្ឋាភិបាលក្នុងការចូលរួម មុនពេលដែលគម្រោងទាំងអស់នេះត្រូវបានអនុម័ត ។

យោងតាមការស្នើសុំឲ្យបង្កើតជាទីសក្ការៈ កន្លែងសម្រាប់ រំឭកពិធីកម្មវិធីអប់រំមួយចំនួន និងការព្យាបាលខាងផ្លូវចិត្ត អង្គជំនុំជម្រះសាលាដំបូងសង្កត់ធ្ងន់ថា ដើមឡើយ ដើមបណ្ដឹងរដ្ឋប្បវេណីទាមទារថា រាល់ការស្នើសុំត្រូវតែបញ្ជាក់ឲ្យលម្អិត និងសមរម្យ ជាឧទាហរណ៍ដូចជា ព័ត៌មានជាក់លាក់អំពីទីតាំង តម្លៃ និងកន្លែងដែលពាក់ព័ន្ធ និងមានការអនុញ្ញាតពីម្ចាស់ដី ព្រមទាំងតម្រូវការសម្រាប់អាជ្ញាធរ កិច្ច ការរដ្ឋបាល ដូចជាអគារសម្រាប់ធ្វើការ ។ ដូចគ្នានេះដែរ ក្នុងអនុស្សារណៈថ្មីនេះ អង្គ

អង្គជំនុំជម្រះសាលាដំបូងបាននិយាយថា នៅក្នុងសំណៅឯកសារលម្អិតនេះ ដែលរៀបរាប់ពីការស្នើសុំទីតាំងរំឭកពិធីគឺជាលក្ខខណ្ឌដំបូងតែប៉ុណ្ណោះសម្រាប់ការអនុម័ត ។ មេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះនឹងព្យាយាមស្វែងរក នូវព័ត៌មានលម្អិតបន្ថែមទៀតបញ្ចូលនៅក្នុងគម្រោងស្នើសុំផ្សេងៗទៀត ដូចជា ថាតើអ្នកណាដែលនឹងមានការទទួលខុសត្រូវលើការបង្កើតនិងការផ្ដល់នូវវិធីសាស្ត្រព្យាបាលដល់សក្ខីជន និងក្រុមស្ម័យ ជំនួយបញ្ជាក់ពីការបរិច្ចេទច្បាស់លាស់ កំឡុងពេលក្នុងការអនុវត្តគម្រោងនេះ និងថាតើមានការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលណាខ្លះ ដែលបានរៀបតាមលំដាប់អាស្រ័យតាមជំនួយមូលនីធិ ។

ដូច្នេះ ថ្វីត្បិតតែអង្គជំនុំជម្រះសាលាដំបូង មានការសាក ល្បងអនុម័តលើសំណើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅតែមានភាពស្រពិចស្រពិល លុះត្រាតែមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី មានលទ្ធភាពគ្រប់គ្រាន់លើផ្នែកទ្រទ្រង់ជនរងគ្រោះក្នុងការទទួលយកការជ្រោមជ្រែងខាងរដ្ឋាភិបាល បញ្ចូលបន្ថែមនូវរាល់ព័ត៌មានលម្អិតនៅក្នុងសំណើសុំ និងធានាបាននូវមូលនិធិចាំបាច់សម្រាប់រយៈពេលខ្លីសមរម្យ ដែលនៅសល់មុនការបិទសាលក្រមនេះ ។ អង្គជំនុំជម្រះសាលាដំបូង បានស្នើសុំមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីឲ្យផ្ដល់នូវព័ត៌មានបន្ថែមឲ្យបានត្រឹមថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ព្រមទាំងរៀបចំតាមលំដាប់ការដាក់សេចក្ដីសន្និដ្ឋាន ចុងក្រោយនូវសំណើសុំសំណងជួសជុលការខូចខាតឲ្យបាននូវ ត្រឹមថ្ងៃទី២៦ ខែកញ្ញា ខាងមុខនេះ ។

**-ចប់-**